# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រធានការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC)



នៅព្រឹកថ្ងៃទី២៨ ខែ សីហា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបលោក **Xuejun Jiang** ប្រធានការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) និងសហការី ដើម្បីពិភាក្សាការងារនៅទីស្តីការក្រសួង ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងថ្លែងអំណរគុណចំពោះមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) ដែលបានផ្តល់គម្រោងអភិវឌ្ឍន៍ និងស្រាវជ្រាវជាច្រើននៅកម្ពុជា ជាពិសេសគម្រោងអភិវឌ្ឍន៍វិស័យសូត្ររបស់កម្ពុជា ក្នុងកម្មវិធីពង្រីក និងពិពិធកម្មនៃការនាំចេញ ក្រោមក្របខ័ណ្ឌនៃគម្រោងកម្មវិធីអភិក្រមគ្របដណ្តប់ទូទាំងវិស័យពាណិជ្ជកម្ម (Trade SWap)។ ទាក់ទងការអភិវឌ្ឍន៍លើវិស័យសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើឱ្យ ITC ជួយជំនួយបច្ចេកទេស ទាក់ទងនិងការបណ្តុះបណ្តាលលើជំនាញស្រាវជ្រាវ និងវិភាគទីផ្សារដល់វិស័យសហគ្រាសធុនតូច និងមធ្យម (SMEs) ក៏ដូចជាវិស័យឯកជនផ្សេងៗទៀត ហើយក៏ជាប្រសើរផងដែរ បើមានការចូលរួមពីតំណាងក្រសួង–ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដើម្បីឱ្យពួកគេទទួលបានជំនាញ ដែលអាចអភិវឌ្ឍន៍ខ្លួន អភិវឌ្ឍន៍សហគ្រាស–ស្ថាប័ន និងអាចមានលទ្ធភាពជួយបណ្តុះបណ្តាលបន្តទៅអ្នកពាក់ព័ន្ធដ៏ទៃទៀត ។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានស្នើឱ្យមានការជួយលើការបណ្តុះបណ្តាលផ្នែកអភិវឌ្ឍន៍ការប្រកួតប្រជែង ដែលសំដៅទៅលើការអភិវឌ្ឍន៍ផលិតផល ការស្រាវជ្រាវទីផ្សារ ក៏ដូចជាផែនទីពាណិជ្ជកម្ម (Trade Map) ដើម្បីជំនះបាននូវរបាំងមិនមែនពន្ធគយ សម្រាប់ទំនិញកម្ពុជានាំចេញទៅក្រៅប្រទេស ហើយទទួលបាននូវឧត្តមភាពប្រកួតប្រជែង ក្នុងបរិបទនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលនឹង លេចជារូបរៀងនៅឆ្នាំ២០១៥ ខាងមុខ ។

ដោយមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) ជាឃ្លាំងស្តុកឯកសារយ៉ាងសំខាន់ៗ ទាក់ទងនិងវិស័យអភិវឌ្ឍន៍ និងស្រាវជ្រាវសេដ្ឋកិច្ច–ពាណិជ្ជកម្ម ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ សង្ឃឹមថាៈមជ្ឈមណ្ឌលនឹងជួយបណ្តុះបណ្តាល ជាពិសេសបង្ហាត់បង្រៀនពីរបៀបការស្រាវជ្រាវតាមប្រព័ន្ធ Internet ដើម្បីស្វែងរកឯកសារសំខាន់ៗ នៅក្នុងគេហទំព័ររបស់ITC ដូចជាទីផ្សារផលិតផល ផែនទីពាណិជ្ជកម្ម (Trade Map) និងទំនិញជាសក្តានុពលនាំចេញជាដើម ។



លោក **Xuejun Jiang** ប្រធានការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) បានលើកឡើងពីការវិវឌ្ឍន៍រីកចម្រើននៃគម្រោងអភិវឌ្ឍន៍វិស័យសូត្រនៅកម្ពុជា រយៈពេល ០២ ឆ្នាំកន្លងមក ក្រោមក្របខ័ណ្ឌកម្មវិធីពង្រីក និងធ្វើពិពិធកម្មនៃការនាំចេញផលិតផលសូត្រ(CEDEP) ពីឆ្នាំ២០១២–២០១៥ ។ លោក **Xuejun Jiang** បានបញ្ជាក់ថាមជ្ឈមណ្ឌល ITC មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការជម្រុញការអភិវឌ្ឍន៍វិស័យសូត្រនៅកម្ពុជា ហើយនឹងសហការឱ្យបានកាន់តែស្អិតរមួតជាមួយក្រុមប្រឹក្សាជាតិស្តីពីសូត្រ ដែលបានបង្កើតរួចហើយនៅកម្ពុជា ។ ទាក់ទងការងារបណ្តុះបណ្តាលដែលឯកឧត្តម ទេសរដ្ឋមន្ត្រី បានលើកឡើង លោក **Xuejun Jiang** បានចាប់អារម្មណ៍លើបញ្ហានេះ ហើយនឹងសហការជម្រុញការងារនេះឱ្យលេចចេញជារូបរៀងឡើង ។ ជាមួយគ្នានេះ លោក **Xuejun Jiang** ក៏បានជម្រាប

ជូនថាៈសម្រាប់ការងារវិភាគទីផ្សារ មជ្ឈមណ្ឌល ITC បានអភិវឌ្ឍន៍នូវឧបករណ៍តាមប្រព័ន្ធ Online ចំនួន ០៥ វិស័យ រួមមានៈ ផែនទីពាណិជ្ជកម្ម (Trade Map)- ផែនទីលទ្ធភាពចូលទីផ្សារ (Market Access Map )- ផែនទីវិនិយោគ (Investment Map)- ផែនទីប្រកួតប្រជែងពាណិជ្ជកម្ម (Trade Competitivness Map) –និងផែនទី ស្តង់ដារ (Standard Map) ដែលនេះជាឧបករណ៍ដ៏សំខាន់នៅក្នុង គេហទំព័ររបស់ ITC សម្រាប់អ្នកចង់សិក្សាស្រាវជ្រាវ និងស្វែងយល់ ។

ផ្សេងៀត ក្នុងឱកាសនោះ លោក **Xuejun Jiang** ក៏បានអញ្ជើញឯកឧត្តមផ្ទាល់ រឺចាត់តំណាង ដើម្បីចូលរួមក្នុងវេទិកាពិភពលោកសម្រាប់ការអភិវឌ្ឍន៍ការនាំចេញ (World Export Development Forum) ដែលនឹងប្រព្រឹត្តិទៅពីថ្ងៃទី១៥–១៧ ខែ កញ្ញា ខាងមុខ នៅទីក្រុង Kigali នៃប្រទេស Rwanda និងមួយទៀតបានស្នើឱ្យ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចាត់តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចូលរួមក្នុងសិក្ខាសាលាស្តីពីការអភិវឌ្ឍន៍ពាណិជ្ជកម្មចិន ជាមួយប្រទេសកម្ពុជា–ឡាវ និងមីយ៉ាន់ម៉ា រៀបចំដោយមជ្ឈមណ្ឌល ITC ក្នុងគម្រោងលើកកំពស់សមត្ថភាពនាំចេញ សម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួចនៅអាស៊ី សម្រាប់ពាណិជ្ជកម្មក្នុងតំបន់ ដែលនឹងប្រារព្ធធ្វើនៅទីក្រុង ណាន់នីង តំបន់ស្វយ័តក្វាងស៊ីឈួង នៃប្រទេសចិន នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ២០១៤ ខាងមុខ ។

ជាការឆ្លើយតប ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបញ្ជាក់ថា៖ការអញ្ជើញភាគីកម្ពុជាឱ្យចូលរួមក្នុងវេទិកាពិភពលោកសម្រាប់ការអភិវឌ្ឍន៍ការនាំចេញ គឺកម្ពុជានឹងអាចចូលរួមនៅឆ្នាំក្រោយ ដោយឆ្នាំនេះចំពេលវេលាមិនអំណោយផល ។ ចំពោះការអញ្ជើញឱ្យចូលរួមក្នុង ក្នុងសិក្ខាសាលាស្តីពីការអភិវឌ្ឍន៍ពាណិជ្ជកម្មចិន ជាមួយប្រទេសកម្ពុជា–ឡាវ និងមីយ៉ាន់ម៉ា ឯកឧត្តមទេសរដ្ឋមន្ត្រីនឹងចាត់ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញមួយចំនួនចូលរួម ហើយក៏បានស្នើឱ្យ ITC រៀបចំសិក្ខាសាលាដូចគ្នានេះនៅកម្ពុជា តាមពេលវេលាសមស្របណាមួយផងដែរ ។

